ក្រុមប្រឹក្សាអ្នកច្បាប់
អគ្គលេខាធិការដ្ឋាន
ចូល
លេខ: ៧៤៣
ថ្ងៃ: ព្រ. ទី១ ខែកក្កដា ឆ្នាំ ២០២០
ម៉ោង: ១៥:៣០ នាទី

# ព្រះរាជក្រម

នស/រកម/០៦២០/០២១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់

# ស្តីពី

# ការប្រឆាំងការសម្អាតប្រាក់
# និងហិរញ្ញប្បទានភេរវកម្ម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-** គោលបំណង

ច្បាប់នេះមានគោលបំណងធានាប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដោយកំណត់អំពីវិធានការត្រួតពិនិត្យ បង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

**មាត្រា២ .-** វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-** និយមន័យនៃពាក្យបច្ចេកទេស

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

១- **ការសម្អាតប្រាក់** សំដៅដល់៖

ក- ការបំប្លែងឬការផ្ទេរទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិនេះជាផលនៃបទល្មើសក្នុងគោលបំណងបិទបាំង ឬក្លែងប្រភពដើមមិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនេះ ឬជួយបុគ្គលណាដែលបានពាក់ព័ន្ធក្នុងបទល្មើស ដើម្បីឱ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន។

ខ- ការបិទបាំងឬការក្លែងសភាវៈពិត ប្រភព ទីតាំង សិទ្ធិចាត់ចែង ចលនា ឬកម្មសិទ្ធិ ឬសិទ្ធិលើទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស។

គ- ការធ្វើលទ្ធកម្ម ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស។

ឃ- ការចូលរួម ការប៉ុនប៉ងប្រព្រឹត្ត ដោយជួយនិងជំរុញឱ្យប្រព្រឹត្តសកម្មភាពណាមួយដែលបានកំណត់ស្របតាមកថាខណ្ឌទី១នៃមាត្រា៣នៃច្បាប់នេះ។

២- **ផលនៃបទល្មើស** សំដៅដល់ទ្រព្យសម្បត្តិណាដែលបាន ឬទទួលដោយផ្ទាល់ ឬដោយប្រយោលតាមរយៈការប្រព្រឹត្តបទល្មើសឧក្រិដ្ឋឬបទល្មើសមជ្ឈិម។

៣- **ទ្រព្យសម្បត្តិ** សំដៅដល់ទ្រព្យគ្រប់ប្រភេទ ចលនទ្រព្យឬអចលនទ្រព្យ ទ្រព្យរូបិយឬទ្រព្យអរូបិយ និងឯកសារឬឧបករណ៍គតិយុត្ត ដែលជាភស្តុតាងនៃកម្មសិទ្ធិឬអត្ថប្រយោជន៍លើទ្រព្យទាំងនេះ។ ទ្រព្យសម្បត្តិរួមបញ្ចូលឧបករណ៍និងផលបានមកពីការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងបទល្មើសធ្ងន់ធ្ងរផ្សេងៗ។ ទ្រព្យសម្បត្តិរួមបញ្ចូលទ្រព្យសម្បត្តិជំនួសរបស់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានតម្លៃស្មើនឹងទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការបង្កក ការឃាត់ទុក និងការរឹបអូស។

៤- **ក្រសួង ស្ថាប័នត្រួតពិនិត្យ** សំដៅដល់ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រ និងក្រសួង ស្ថាប័នផ្សេងទៀត ដែលត្រួតពិនិត្យលើបុគ្គលរាយការណ៍។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៥- **សំអាងនៃបទល្មើស** សំដៅដល់បទល្មើសឧក្រិដ្ឋឬបទល្មើសមជ្ឈិម ទោះជាបានប្រព្រឹត្តនៅក្រៅប្រទេសដែលផលទទួលបានពីបទល្មើសទាំងនេះអាចក្លាយជាកម្មវត្ថុនៃការសម្អាតប្រាក់ ដូចបានកំណត់ក្នុងកថាខណ្ឌទី១នៃមាត្រា៣នៃច្បាប់នេះ។ ដើម្បីអាចយកមកប្រើប្រាស់ជាមូលដ្ឋានសម្រាប់ប្ដឹងអំពីការសម្អាតប្រាក់ សំអាងនៃបទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្រៅប្រទេស ត្រូវមានចរិតជាបទល្មើសនៅក្នុងប្រទេសដែលបទល្មើសនេះត្រូវបានប្រព្រឹត្តនិងស្ថិតនៅក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាការកំណត់ឈ្មោះបទល្មើសខុសគ្នាក្តី។

៦- **ហិរញ្ញប្បទានភេរវកម្ម** សំដៅដល់ការផ្តល់ឬការប្រមូលដោយចេតនានូវទ្រព្យសម្បត្តិ មូលនិធិ ឬសេវាផ្សេងៗក្នុងបំណងប្រើប្រាស់ ឬដោយដឹងថាទ្រព្យសម្បត្តិ មូលនិធិ ឬសេវានេះ នឹងត្រូវបាន ឬអាចប្រើប្រាស់ទាំងមូល ឬមួយផ្នែកសម្រាប់គាំទ្រពល់សកម្មភាព ជាអាទិ៍ ការធ្វើដំណើរ ការបណ្តុះបណ្តាល ការរៀបចំ ការចូលរួម ឬការប្រព្រឹត្តអំពើភេរវកម្ម របស់ភេរវករឬអង្គការចាត់តាំងរបស់ភេរវកម្ម។

៧- **ប្រតិបត្តិការសង្ស័យ** សំដៅដល់ប្រតិបត្តិការឬការប៉ុនប៉ងធ្វើប្រតិបត្តិការទាក់ទងទៅនឹងមូលនិធិដែលត្រូវបានសង្ស័យថាបានមកពីការប្រព្រឹត្តបទល្មើសឬមូលនិធិទាក់ទងនឹងហិរញ្ញប្បទានភេរវកម្ម។

៨- **ប្រតិបត្តិការសាច់ប្រាក់** សំដៅដល់ប្រតិបត្តិការទាំងឡាយណាដែលត្រូវបានធ្វើឡើងជាសាច់ប្រាក់ឬប្រភេទប្រតិបត្តិការផ្សេងទៀតដែលមានចំនួនកំណត់។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវចេញសេចក្តីណែនាំកំណត់ចំនួននេះ។

៩- **អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា** សំដៅដល់អង្គការកណ្តាលដែលទទួលខុសត្រូវក្នុងការទទួលនិងវិភាគរបាយការណ៍ប្រតិបត្តិការសង្ស័យ ដូចបានកំណត់ក្នុងកថាខណ្ឌទី៧នៃមាត្រា៣នៃច្បាប់នេះ របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ ដូចបានកំណត់ក្នុងកថាខណ្ឌទី៨នៃមាត្រា៣នៃច្បាប់នេះ និងបញ្ជូនលទ្ធផលនៃការវិភាគនិងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងការសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម។

១០- **អត្ថគាហកចុងក្រោយ** សំដៅដល់រូបវន្តបុគ្គលដែលកាន់កាប់ឬត្រួតត្រាចុងក្រោយបង្អស់លើអតិថិជន និង/ឬរូបវន្តបុគ្គលដែលធ្វើប្រតិបត្តិការជំនួស។

នៅពេលអតិថិជនគឺជានីតិបុគ្គល អត្ថគាហកចុងក្រោយគឺៈ

- ក- រូបវន្តបុគ្គលដែលកាន់កាប់ឬគ្រប់គ្រងចុងក្រោយបង្អស់ ដោយផ្ទាល់ឬប្រយោលលើនីតិបុគ្គលតាមរយៈការកាន់កាប់ភាគហ៊ុនឬសិទ្ធិបោះឆ្នោតដែលចំនួនភាគរយត្រូវកំណត់ដោយសេចក្តីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ឬ
- ខ- រូបវន្តបុគ្គលដែលកាន់កាប់តាមរយៈមធ្យោបាយផ្សេងៗ នៅពេលដែលមិនមានរូបវន្តបុគ្គលមានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ឬពុំអាចកំណត់បុគ្គលដែលកំពុងកាន់កាប់កម្មសិទ្ធិជាអត្ថគាហកចុងក្រោយ។

១១- **បុគ្គលពាក់ព័ន្ធនយោបាយ** សំដៅដល់ឯកត្តជនដែលជាបុគ្គលពាក់ព័ន្ធនយោបាយក្នុងស្រុក បុគ្គលពាក់ព័ន្ធនយោបាយបរទេសឬបុគ្គលពាក់ព័ន្ធនយោបាយអន្តរជាតិ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ក- បុគ្គលពាក់ព័ន្ធនយោបាយក្នុងស្រុក សំដៅដល់ឯកត្តជនដែលជាឬដែលត្រូវបានប្រគល់មុខងារសាធារណៈខ្ពង់ខ្ពស់របស់ព្រះរាជាណាចក្រកម្ពុជា ដូចជា អ្នកនយោបាយជាន់ខ្ពស់ មន្ត្រីរាជរដ្ឋាភិបាលជាន់ខ្ពស់ មន្ត្រីយោធាឬមន្ត្រីយុត្តិធម៌ជាន់ខ្ពស់ នាយកប្រតិបត្តិជាន់ខ្ពស់នៃសាជីវកម្មរដ្ឋ ឬមន្ត្រីសំខាន់ៗរបស់គណបក្សនយោបាយ។

ខ- បុគ្គលពាក់ព័ន្ធនយោបាយបរទេស សំដៅដល់ឯកត្តជនដែលជាឬដែលត្រូវបានប្រគល់មុខងារសាធារណៈខ្ពង់ខ្ពស់នៅក្រៅប្រទេស ដូចជាប្រមុខរដ្ឋឬប្រមុខរដ្ឋាភិបាល អ្នកនយោបាយជាន់ខ្ពស់ មន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ មន្ត្រីយោធាឬមន្ត្រីយុត្តិធម៌ នាយកប្រតិបត្តិជាន់ខ្ពស់នៃសាជីវកម្មរដ្ឋ ឬមន្ត្រីគណបក្សសំខាន់ៗ។

គ- បុគ្គលពាក់ព័ន្ធនយោបាយអន្តរជាតិ សំដៅដល់ឯកត្តជនរបស់អង្គការអន្តរជាតិដែលជាឬដែលត្រូវបានប្រគល់មុខងារសាធារណៈខ្ពង់ខ្ពស់ ដូចជា សមាជិកគណៈគ្រប់គ្រងជាន់ខ្ពស់ ឬសមាជិកក្រុមប្រឹក្សាភិបាល ឬសមាជិកអង្គការចាត់តាំងប្រហាក់ប្រហែលណាមួយ។

១២- **ក្រុមហ៊ុនអាណត្តិព្យាបាល** សំដៅដល់នីតិបុគ្គលដែលត្រូវបានបង្កើតឡើងដោយបុគ្គលម្នាក់ដែលជាអ្នកប្រគល់អាណត្តិព្យាបាល។ អ្នកប្រគល់អាណត្តិព្យាបាលផ្ទេរកម្មសិទ្ធិស្របច្បាប់នៃទ្រព្យសម្បត្តិទៅឱ្យអ្នកទទួលអាណត្តិព្យាបាលដែលធ្វើការគ្រប់គ្រងទ្រព្យសម្បត្តិនោះ សម្រាប់ជាផលប្រយោជន៍ដល់អត្ថគាហកណាម្នាក់ច្បាស់លាស់។

១៣- **កិច្ចសម្របសម្រួលផ្លូវច្បាប់** សំដៅដល់៖

ក- កិច្ចការគ្រប់គ្រងនិងចាត់ចែងបរធនដែលផ្តល់ដោយបរធនបាលទាយកសម្រាប់ជាប្រយោជន៍ដល់អត្ថគាហក ដោយអនុលោមតាមលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

ខ- ទំនាក់ទំនងផ្លូវច្បាប់ដទៃទៀត ដែលបង្កើតឡើងដោយបុគ្គលដែលផ្ទេរកម្មសិទ្ធិឬសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិដល់បុគ្គលផ្សេងទៀតដែលត្រូវអនុវត្តតាមកាតព្វកិច្ចគ្រប់គ្រងឬចាត់ចែងជំនួសឱ្យអត្ថគាហក ឬប្រភេទនៃអត្ថគាហកផ្សេងៗ ឬសម្រាប់គោលបំណងជាក់លាក់ណាមួយ។

១៤- **ទុព្វលកម្ម** សំដៅដល់ការធ្វើឱ្យទៅជាមោឃៈ។

១៥- **វិធានការប្រឆាំង** សំដៅដល់សេចក្តីណែនាំដែលចេញដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាឱ្យបុគ្គលរាយការណ៍អនុវត្តស្របតាមកថាខណ្ឌទី១៤នៃមាត្រា៨នៃច្បាប់នេះ ដែលមានចំណុចមួយឬច្រើន ដូចខាងក្រោម៖

ក- ការអនុវត្តវិធានការបន្ថឹងការយកចិត្តទុកដាក់ស្គាល់អតិថិជន ចំពោះប្រតិបត្តិការដែលពាក់ព័ន្ធនឹងយុត្តាធិការមានហានិភ័យខ្ពស់។

ខ- ការតាមដានពិសេស និង/ឬការរាយការណ៍ប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងយុត្តាធិការមានហានិភ័យខ្ពស់។

គ- ការហាមឃាត់ការចូលរួម ឬធ្វើប្រតិបត្តិការហិរញ្ញវត្ថុ ឬប្រភេទប្រតិបត្តិការហិរញ្ញវត្ថុផ្សេងៗណាមួយ ជាមួយយុត្តាធិការមានហានិភ័យខ្ពស់។

ឃ- បទបញ្ញាផ្សេងៗ ដើម្បីកាត់បន្ថយហានិភ័យសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្មដែលបណ្ដាលមកពីយុត្តាធិការមានហានិភ័យខ្ពស់។

១៦- **ទណ្ឌកម្មហិរញ្ញវត្ថុតាមគោលដៅ** សំដៅដល់ច្បាប់ឬបទប្បញ្ញត្តិណាមួយ ដើម្បីអនុវត្តសេចក្ដីសម្រេចដែលចេញដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ក្រោមបញ្ញត្តិនៃជំពូកទី៧នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។

១៧- **ឧបករណ៍មធ្យោបាយប្រព្រឹត្តបទល្មើស** សំដៅដល់ឧបករណ៍ដែលជាទ្រព្យដែលត្រូវបានប្រើប្រាស់ឬប៉ុនប៉ងប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស។

## ជំពូកទី២
## បុគ្គលរាយការណ៍

**មាត្រា៤ .-** បុគ្គលនិងវិជ្ជាជីវៈចំណុះច្បាប់នេះ

ច្បាប់នេះត្រូវអនុវត្តចំពោះបុគ្គលនិងវិជ្ជាជីវៈដូចខាងក្រោម ដែលតទៅនេះហៅថា បុគ្គលរាយការណ៍៖

១- ធនាគារ រួមទាំងសាខារបស់ធនាគារបរទេស។

២- គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ រួមមានក្រុមហ៊ុនជើងសារមូលបត្រនិងក្រុមហ៊ុនធានារ៉ាប់រង។

៣- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

៤- សហករណ៍ឥណទាន។

៥- ក្រុមហ៊ុនភតិសន្យា មូលនិធិសោធននិងវិនិយោគ ក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនគ្រប់គ្រងមូលនិធិវិនិយោគ។

៦- អាជីវកម្មប្ដូរប្រាក់។

៧- សេវាផ្ទេរប្រាក់។

៨- បរធនបាលកិច្ច។

៩- ភ្នាក់ងារ ក្រុមហ៊ុន អ្នកអភិវឌ្ឍន៍អចលនទ្រព្យ អគារ និងដីធ្លី។

១០- ឈ្មួញលោហធាតុ ត្បូងថ្មមានតម្លៃ។

១១- ការិយាល័យប្រៃសណីយ៍ដែលធ្វើប្រតិបត្តិការទូទាត់សងប្រាក់។

១២- មេធាវី សារការី គណនេយ្យករ សវនករ ទីប្រឹក្សាវិនិយោគ និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ នៅពេលដែលអ្នកទាំងនោះរៀបចំឬធ្វើប្រតិបត្តិការទាក់ទងទៅនឹងសកម្មភាពបម្រើឱ្យអតិថិជនរបស់ខ្លួនដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ។

១៣- កាស៊ីណូនិងគ្រឹះស្ថានល្បែងស៊ីសងផ្សេងៗ។

១៤- អង្គការមិនមែនរដ្ឋាភិបាល និងអង្គការមូលនិធិធ្វើសកម្មភាពអាជីវកម្ម និងរៃអង្គាសមូលនិធិ។

១៥- បុគ្គលឬវិជ្ជាជីវៈផ្សេងទៀតកំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាដែលត្រូវស្ថិតក្នុងដែនអនុវត្តនៃច្បាប់នេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៥ .- សកម្មភាពអាជីវកម្មនៃបុគ្គលរាយការណ៍**

សកម្មភាពអាជីវកម្មនៃបុគ្គលរាយការណ៍ ដូចមានក្នុងកថាខណ្ឌទី១២នៃមាត្រា៤នៃច្បាប់នេះ រួមមាន៖

១- ការទិញនិងលក់អចលនទ្រព្យ អគារ និងដីធ្លី។

២- ការគ្រប់គ្រងប្រាក់ មូលបត្រ ឬទ្រព្យសកម្មផ្សេងទៀតរបស់អតិថិជន ដូចជា៖

ក- ការគ្រប់គ្រងគណនីធនាគារឬគណនីមូលបត្រ។

ខ- ការចូលរួមចំណែកក្នុងការបង្កើតប្រតិបត្តិការឬគ្រប់គ្រងក្រុមហ៊ុន។

៣- ការបង្កើតប្រតិបត្តិការ ឬគ្រប់គ្រងនីតិបុគ្គល ឬកិច្ចសម្របសម្រួល និងការទិញនិងលក់អង្គភាពអាជីវកម្ម។

៤- ក្រុមហ៊ុនអាណត្តិព្យាបាលឬក្រុមហ៊ុនដែលផ្តល់សេវានៅពេលដែលក្រុមហ៊ុនទាំងនោះត្រៀមអនុវត្តឬអនុវត្តសម្រាប់អតិថិជនទាក់ទងនឹងសកម្មភាពទាំងឡាយ ដូចខាងក្រោម៖

ក- ធ្វើសកម្មភាពជាភ្នាក់ងារបង្កើតនីតិបុគ្គលនោះ។

ខ- ធ្វើសកម្មភាពឬរៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាព ជានាយកឬជាលេខាធិការរបស់ក្រុមហ៊ុន ជាអ្នកចូលហ៊ុននៃក្រុមហ៊ុនសហកម្មសិទ្ធិឬតួនាទីប្រហាក់ប្រហែលទាក់ទងជាមួយនីតិបុគ្គលផ្សេងទៀត។

គ- ផ្តល់ទីស្នាក់ការផ្លូវការ អាសយដ្ឋានឬទីតាំងអាជីវកម្ម អាសយដ្ឋានទំនាក់ទំនងឬរដ្ឋបាលសម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិ ឬនីតិបុគ្គលដទៃទៀត ឬការសម្របសម្រួលដទៃទៀត។

ឃ- ធ្វើសកម្មភាពឬរៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាពជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនអាណត្តិព្យាបាល។

ង- ធ្វើសកម្មភាពឬរៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាពជាភាគទុនិកដែលត្រូវបានតែងតាំងជំនួសឱ្យបុគ្គលដទៃ។

## ជំពូកទី៣
## វិធានការត្រូវប្រកាន់យកដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មុខរបរហិរញ្ញវត្ថុមិនមែនធនាគារនិងវិជ្ជាជីវៈ ដើម្បីទប់ស្កាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

**មាត្រា៦ .- ការសម្ងាត់ធនាគារនិងវិជ្ជាជីវៈ**

ការសម្ងាត់ធនាគារឬវិជ្ជាជីវៈមិនត្រូវរារាំងការអនុវត្តច្បាប់នេះ និងមិនអាចយកមកប្រើជាសំអាងដើម្បីបដិសេធការផ្តល់ព័ត៌មានដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងក្រសួង ស្ថាប័នត្រួតពិនិត្យ ទោះបីសម្រាប់គោលបំណងសហប្រតិបត្តិការក្នុងប្រទេសឬអន្តរជាតិ ឬក៏ដូចដែលបានតម្រូវក្នុងការស៊ើបអង្កេតពាក់ព័ន្ធនឹងការសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្មដែលត្រូវបានបញ្ជាដោយឬអនុវត្តក្រោមការត្រួតពិនិត្យផ្នែកព្រហ្មទណ្ឌ។

**មាត្រា៧ .- ការហាមឃាត់គណនីអនាមិកឬផលិតផលសទិស**

បុគ្គលរាយការណ៍មិនត្រូវ៖

១- បើកឬរក្សាទុកគណនីអនាមិក ឬគណនីដែលមានតែលេខឬគណនីដែលដាក់ឈ្មោះបតិដ្ឋកម្ម។
២- ចេញផ្សាយ រក្សាទុក ឬទទួលយកផលិតផលហិរញ្ញវត្ថុផ្សេងទៀត លើកលែងតែបានអនុវត្តវិធានការយកចិត្តទុកដាក់ចំពោះអតិថិជនស្របតាមមាត្រា៨នៃច្បាប់នេះ។

**មាត្រា៨ .- វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន**

១- បុគ្គលរាយការណ៍នៅក្នុងមាត្រា៤នៃច្បាប់នេះ ត្រូវអនុវត្តវិធីសាស្ត្រផ្អែកលើហានិភ័យ ដើម្បីគ្រប់គ្រងនិងកាត់បន្ថយហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់ខ្លួន។ ផ្អែកលើវិធីសាស្ត្រនេះបុគ្គលរាយការណ៍ត្រូវវាយតម្លៃ និងយល់ដឹងអំពីហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មរបស់ខ្លួន និងត្រូវអនុវត្តវិធានការសមស្របមួយក្នុងការយកចិត្តទុកដាក់ស្គាល់អតិថិជន ដើម្បីគ្រប់គ្រងនិងកាត់បន្ថយហានិភ័យនេះ។ បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការបន្តឹងការយកចិត្តទុកដាក់ស្គាល់អតិថិជននៅពេលរកឃើញថាមានហានិភ័យខ្ពស់ និងអាចអនុវត្តវិធានការសាមញ្ញនៃការយកចិត្តទុកដាក់ស្គាល់អតិថិជននៅពេលរកឃើញថាមានហានិភ័យទាប។

២- កាតព្វកិច្ចសម្រាប់អនុវត្តវិធានការបន្តឹងការយកចិត្តទុកដាក់ស្គាល់អតិថិជននិងវិធានការសាមញ្ញនៃការយកចិត្តទុកដាក់ស្គាល់អតិថិជន ត្រូវកំណត់នៅក្នុងសេចក្តីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

៣- ក្នុងគោលបំណងអនុវត្តការវាយតម្លៃហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ បុគ្គលរាយការណ៍ត្រូវអនុវត្តតាមសេចក្តីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

៤- បុគ្គលរាយការណ៍ត្រូវប្រកាន់យកវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់ខ្លួនឱ្យបានច្បាស់លាស់ រួមមាន ការកំណត់ និងការផ្ទៀងផ្ទាត់អត្តសញ្ញាណ ជាដើម ដូចជា៖

ក- មុនពេលបង្កើតទំនាក់ទំនងអាជីវកម្ម ដូចជា ការបើកគណនី ការទទួលថែរក្សាភាគហ៊ុន សញ្ញាប័ណ្ណឬមូលបត្រផ្សេងៗក្នុងទូសុវត្ថិភាព ការផ្តល់សេវាប្រអប់សុវត្ថិភាព ឬការចូលរួមប្រកបអាជីវកម្មផ្សេងទៀតជាមួយគ្នា។

ខ- មុនពេលអនុវត្តប្រតិបត្តិការម្តងម្កាលឬតែមួយដង ដែលមានចំនួនស្មើឬលើសពីចំនួនកំណត់នៅក្នុងសេចក្តីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដូចជា ការផ្ទេរប្រាក់តាមអេឡិចត្រូនិកត្រូវមានព័ត៌មានពាក់ព័ន្ធនឹងអ្នកផ្តើមប្រតិបត្តិការនិងអត្ថគាហកចុងក្រោយ ក្នុងករណីដែលមានគណនីត្រូវមានលេខគណនី ហើយក្នុងករណីដែលគ្មានគណនីត្រូវដាក់តែលេខយោង។

គ- ក្នុងករណីបុគ្គលរាយការណ៍មានការសង្ស័យពីការសម្អាតប្រាក់ និង/ឬហិរញ្ញប្បទានភេរវកម្ម ដោយមិនគិតពីបរិមាណប្រាក់នៃប្រតិបត្តិការ។

ឃ- ក្នុងករណីមានការសង្ស័យអំពីភាពស្មោះត្រង់ឬភាពគ្រប់គ្រាន់លើទិន្នន័យនៃអត្តសញ្ញាណរបស់អតិថិជនដែលបានទទួលពីមុនមកហើយ។

បុគ្គលរាយការណ៍ត្រូវចាត់វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ដូចខាងក្រោម៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ក- សម្គាល់អត្តសញ្ញាណរបស់អតិថិជនដោយទទួលបានជាអប្បបរមានូវ នាម នាមត្រកូល ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានសម្រាប់រូបវន្តបុគ្គល និងនាមករណ៍ លក្ខន្តិកៈឬការចុះបញ្ជី ប័ណ្ណបង់ពន្ធ អាសយដ្ឋាន លេខទូរស័ព្ទ ជាដើមសម្រាប់នីតិបុគ្គល ដូចបានកំណត់នៅក្នុងសេចក្ដីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងផ្ទៀងផ្ទាត់ថាអតិថិជនបានប្រើប្រាស់ឯកសារ ទិន្នន័យឬព័ត៌មាន ដែលមានប្រភពឯករាជ្យគួរឱ្យជឿទុកចិត្តបានក្នុងការផ្ដល់អត្តសញ្ញាណរបស់ខ្លួន ដូចជា អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងឯកសារអត្តសញ្ញាណផ្លូវការមានរូបថត។

ខ- សម្គាល់អត្តសញ្ញាណអត្ថគាហកចុងក្រោយនិងចាត់វិធានការសមស្រប ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណអត្ថគាហកតាមវិធីដែលបុគ្គលរាយការណ៍បានប្រាកដក្នុងចិត្តថា អត្ថគាហកចុងក្រោយត្រូវបានស្គាល់ច្បាស់លាស់។ សម្រាប់នីតិបុគ្គលឬកិច្ចសម្របសម្រួលផ្លូវច្បាប់ បុគ្គលរាយការណ៍ត្រូវចាត់វិធានការសមស្របដើម្បីស្វែងយល់ពីចរិតលក្ខណៈអាជីវកម្ម ភាពជាម្ចាស់កម្មសិទ្ធិ និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់អតិថិជន។ នៅពេលពុំអាចកំណត់បានថារូបវន្តបុគ្គលគឺជាអត្ថគាហកចុងក្រោយរបស់នីតិបុគ្គល បុគ្គលដែលកាន់កាប់មុខតំណែងជាមន្ត្រីគ្រប់គ្រងជាន់ខ្ពស់ ត្រូវបានចាត់ទុកថាជាអត្ថគាហកចុងក្រោយ។

គ- ទទួលព័ត៌មានពីគោលបំណងនិងប្រភេទនៃទំនាក់ទំនងអាជីវកម្ម។

ឃ- សម្គាល់អត្តសញ្ញាណអតិថិជន ឬអត្ថគាហកចុងក្រោយជាបុគ្គលពាក់ព័ន្ធនយោបាយ ឬជាសមាជិកគ្រួសារ ឬសមាគតជិតស្និទ្ធរបស់បុគ្គលពាក់ព័ន្ធនយោបាយ និងអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជននោះ ស្របតាមកម្រិតហានិភ័យដែលបានវាយតម្លៃនិងកាតព្វកិច្ចនៃច្បាប់នេះ និងសេចក្ដីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

ង- បន្តយកចិត្តទុកដាក់ទៅលើទំនាក់ទំនងអាជីវកម្ម ជាអាទិ៍៖
   - ពិនិត្យពិច័យប្រតិបត្តិការទាំងឡាយដែលបានប្រព្រឹត្តទៅក្នុងពេលទំនាក់ទំនងនេះ ដើម្បីធានាថាប្រតិបត្តិការទាំងនេះស្របទៅតាមគោលការណ៍ស្គាល់អតិថិជន មុខរបរ និងទ្រង់ទ្រាយហានិភ័យរបស់បុគ្គលរាយការណ៍ទាំងនោះ រួមទាំងប្រភពមូលនិធិផង បើចាំបាច់។
   - ធ្វើបច្ចុប្បន្នកម្មឱ្យបានពេញលេញនូវឯកសារ ទិន្នន័យឬព័ត៌មានដែលប្រមូលបានក្នុងដំណើរការយកចិត្តទុកដាក់ស្គាល់អតិថិជន តាមរយៈការពិនិត្យឡើងវិញនូវកំណត់ត្រាដែលមានស្រាប់ ជាពិសេសប្រភេទអតិថិជនដែលមានហានិភ័យខ្ពស់។

៦- នៅពេលបុគ្គលរាយការណ៍មិនអាចអនុវត្តតាមកថាខណ្ឌទី៥នៃមាត្រានេះ បុគ្គលរាយការណ៍នោះមិនត្រូវបើកគណនី មិនត្រូវចាប់ផ្ដើមទំនាក់ទំនងអាជីវកម្មឬមិនត្រូវអនុវត្តប្រតិបត្តិការ ឬក្នុងករណីមានទំនាក់ទំនងអាជីវកម្មជាមួយអតិថិជនរួចហើយ ត្រូវបញ្ចប់ទំនាក់ទំនងអាជីវកម្មនោះ លើកលែងតែមានការណែនាំផ្ទុយពីនេះដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។ ក្នុងករណីដូចនេះ បុគ្គលរាយការណ៍ត្រូវពិចារណាធ្វើរបាយការណ៍ប្រតិបត្តិការសង្ស័យពាក់ព័ន្ធនឹងអតិថិជននោះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៧- នៅពេលបុគ្គលរាយការណ៍អនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ហើយបើសង្ស័យថា អតិថិជនអាចជាប់ពាក់ព័ន្ធនឹងការសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម និងជឿជាក់ថាការបន្ត អនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជននឹងធ្វើឱ្យអតិថិជននោះដឹងខ្លួនថាកំពុងត្រូវបាន សង្ស័យ បុគ្គលរាយការណ៍នោះអាចមិនបន្តអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន ហើយត្រូវរាយការណ៍ប្រតិបត្តិការសង្ស័យ។

៨- កាតព្វកិច្ចដែលមានចែងក្នុងកថាខណ្ឌទី៤ ដល់កថាខណ្ឌទី៧នៃមាត្រានេះ ត្រូវអនុវត្តចំពោះ អតិថិជនថ្មីទាំងអស់ ក៏ដូចជាអតិថិជនដែលមានស្រាប់ផ្អែកលើមូលដ្ឋាននៃការពិតនិងហានិភ័យ។ បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការយកចិត្តទុកដាក់ស្គាល់អតិថិជនឡើងវិញ ចំពោះទំនាក់ ទំនងដែលមានស្រាប់។

៩- បុគ្គលរាយការណ៍អាចអនុវត្តវិធានការសាមញ្ញនៃការយកចិត្តទុកដាក់ស្គាល់អតិថិជន នៅពេល វាយតម្លៃឃើញមានហានិភ័យសម្អាតប្រាក់ និង/ឬហិរញ្ញប្បទានភេរវកម្មទាប ស្របតាម កាតព្វកិច្ចដូចបានកំណត់នៅក្នុងសេចក្ដីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

១០- បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការបន្ថែមការយកចិត្តទុកដាក់ស្គាល់អតិថិជនចំពោះទំនាក់ ទំនងអាជីវកម្ម ឬប្រតិបត្តិការដែលមានចែងក្នុងមាត្រា១០នៃច្បាប់នេះ និងទំនាក់ទំនងអាជីវកម្ម ឬប្រតិបត្តិការផ្សេងទៀត ដូចខាងក្រោម៖

ក- ទំនាក់ទំនងអាជីវកម្មនិងប្រតិបត្តិការជាមួយគ្រឹះស្ថាន ឬបុគ្គលក្នុងយុត្តាធិការដែលមាន ហានិភ័យសម្អាតប្រាក់ និង/ឬហិរញ្ញប្បទានភេរវកម្មខ្ពស់។

ខ- ទំនាក់ទំនងអាជីវកម្មនិងប្រតិបត្តិការជាមួយបុគ្គលពាក់ព័ន្ធនយោបាយបរទេស និងជាមួយ បុគ្គលជាសមាជិកគ្រួសារឬជាសមាគតជិតស្និទ្ធរបស់បុគ្គលពាក់ព័ន្ធនយោបាយនោះ។

គ- ទំនាក់ទំនងអាជីវកម្មនិងប្រតិបត្តិការជាមួយបុគ្គលពាក់ព័ន្ធនយោបាយក្នុងស្រុក និង បុគ្គលពាក់ព័ន្ធនយោបាយអន្តរជាតិ និងជាមួយបុគ្គលជាសមាជិកគ្រួសារឬជាសមាគត ជិតស្និទ្ធរបស់បុគ្គលពាក់ព័ន្ធនយោបាយនោះ នៅពេលដែលទំនាក់ទំនងអាជីវកម្មឬ ប្រតិបត្តិការនោះត្រូវបានវាយតម្លៃថាមានហានិភ័យខ្ពស់។

ឃ- ប្រតិបត្តិការឬទំនាក់ទំនងដែលត្រូវបានវាយតម្លៃថាមានហានិភ័យសម្អាតប្រាក់ឬ ហិរញ្ញប្បទានភេរវកម្មខ្ពស់។

១១- បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការបន្ថែមការយកចិត្តទុកដាក់ស្គាល់អតិថិជនស្របតាម កម្រិតហានិភ័យខ្ពស់ និងត្រូវអនុវត្តកាតព្វកិច្ចណាមួយផ្សេងទៀតដែលជាប់ទាក់ទងនឹង កថាខណ្ឌទី១០នៃមាត្រានេះ ឬផលិតផលនិងសេវាកម្មមានហានិភ័យខ្ពស់ ដូចបានកំណត់នៅ ក្នុងសេចក្ដីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

១២- បុគ្គលរាយការណ៍ត្រូវធានាឱ្យមានការយល់ដឹងអំពីហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទាន ភេរវកម្ម និងការរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសមស្រប ដូចបានកំណត់នៅក្នុងសេចក្ដីណែនាំ របស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដើម្បីគ្រប់គ្រងនិងកាត់បន្ថយហានិភ័យនេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១៣- បុគ្គលរាយការណ៍ដែលស្ថិតនៅក្នុងក្រុមហិរញ្ញវត្ថុ ឬបុគ្គលរាយការណ៍ដែលមានសាខាបរទេស ឬមានបុគ្គលសម្ព័ន្ធបរទេសដែលខ្លួនកាន់កាប់ភាគហ៊ុនភាគច្រើន ត្រូវអនុវត្តតាមកម្មវិធីរួម ដូចបានកំណត់ក្នុងមាត្រា១៦នៃច្បាប់នេះរបស់ក្រុមហិរញ្ញវត្ថុឱ្យបានសមស្របអំពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ កម្មវិធីនេះ ត្រូវស្របតាមកាតព្វកិច្ចដូចបានកំណត់នៅក្នុងសេចក្ដីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងការវាយតម្លៃហានិភ័យរបស់បុគ្គលរាយការណ៍ ដូចមានចែងក្នុងច្បាប់នេះ។

១៤- បុគ្គលរាយការណ៍ត្រូវអនុវត្តវិធានការប្រឆាំងដូចបានកំណត់នៅក្នុងសេចក្ដីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់កាត់បន្ថយហានិភ័យសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មពីយុត្តាធិការបរទេសដែលបានចាត់ទុកថាសមស្រប ឬតាមការតម្រូវរបស់ក្រុមការងារហិរញ្ញវត្ថុ ឬក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្ដីពីការសម្អាតប្រាក់។

១៥- បុគ្គលរាយការណ៍ត្រូវអនុវត្តឱ្យបានសមស្របនូវទណ្ឌកម្មហិរញ្ញវត្ថុតាមគោលដៅចំពោះអតិថិជន។

១៦- បុគ្គលរាយការណ៍នៅក្នុងកថាខណ្ឌទី៩នៃមាត្រា៤នៃច្បាប់នេះ ត្រូវអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី១ ដល់កថាខណ្ឌទី១៥នៃមាត្រានេះ និងសេចក្ដីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលដាក់ឱ្យប្រើប្រាស់ស្របតាមច្បាប់នេះពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ស្គាល់អតិថិជន នៅពេលធ្វើប្រតិបត្តិការណាមួយ សម្រាប់ឬជាមួយអតិថិជនរបស់ខ្លួន ចំពោះការទិញឬលក់អចលនទ្រព្យ។

១៧- បុគ្គលរាយការណ៍នៅក្នុងកថាខណ្ឌទី១០ និងកថាខណ្ឌទី១៣នៃមាត្រា៤នៃច្បាប់នេះ ត្រូវអនុវត្តបញ្ញត្តិនៃកថាខណ្ឌទី១ដល់កថាខណ្ឌទី១៥នៃមាត្រានេះ និងសេចក្ដីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលដាក់ឱ្យប្រើប្រាស់ស្របតាមច្បាប់នេះ ពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ស្គាល់អតិថិជន នៅពេលធ្វើប្រតិបត្តិការណាមួយជាមួយអតិថិជន ដែលមានទឹកប្រាក់ស្មើឬលើសចំនួនកំណត់ដូចមាននៅក្នុងសេចក្ដីណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

**មាត្រា៩ .- ការសម្គាល់អត្តសញ្ញាណអតិថិជនដែលធ្វើប្រតិបត្តិការក្រោមកម្រិតកំណត់**

ការសម្គាល់អត្តសញ្ញាណក៏ត្រូវអនុវត្តផងដែរក្នុងករណីប្រតិបត្តិការដាច់ៗពីគ្នាត្រូវបានធ្វើជាច្រើនដង ដោយប្រតិបត្តិការនីមួយៗ មានចំនួនប្រាក់តិចជាងចំនួនដែលបានកំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ប៉ុន្តែបុគ្គលរាយការណ៍មានហេតុផលដែលអាចជឿបានថា ប្រតិបត្តិការទាំងនោះត្រូវបានធ្វើឡើងក្នុងគោលបំណងចៀសវាងការសម្គាល់អត្តសញ្ញាណ។

**មាត្រា១០ .- ការតាមដានត្រួតពិនិត្យពិសេសទៅលើប្រតិបត្តិការមួយចំនួន**

បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ជាពិសេសលើ៖

ប្រតិបត្តិការណាដែលស្មុគស្មាញ មិនប្រក្រតី ឬមានចំនួនប្រាក់ច្រើន។

ប្រភេទប្រតិបត្តិការមិនប្រក្រតីដែលមិនបង្ហាញពីគោលបំណងសេដ្ឋកិច្ចឬស្របច្បាប់ច្បាស់លាស់ណាមួយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គ- ទំនាក់ទំនងអាជីវកម្មនិងប្រតិបត្តិការជាមួយគ្រឹះស្ថាន ឬបុគ្គលក្នុងយុត្តាធិការដែលមិនមានប្រព័ន្ធគ្រប់គ្រាន់សម្រាប់បង្ការ ឬរារាំងសកម្មភាពសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម។

ឃ- ការផ្ទេរប្រាក់តាមអេឡិចត្រូនិកដែលពុំមានព័ត៌មានរបស់អ្នកផ្តើមប្រតិបត្តិការគ្រប់គ្រាន់។

ង- ទំនាក់ទំនងអាជីវកម្មនិងប្រតិបត្តិការជាមួយបុគ្គលណាដែលបុគ្គលរាយការណ៍មិនបានជួបប្រាស្រ័យផ្ទាល់នៅពេលអនុវត្តនីតិវិធីសម្គាល់អត្តសញ្ញាណ។

ច- ទំនាក់ទំនងអាជីវកម្មនិងប្រតិបត្តិការជាមួយបុគ្គលពាក់ព័ន្ធនយោបាយ។

ឆ- ទំនាក់ទំនងអាជីវកម្ម និងប្រតិបត្តិការដែលធ្វើតាមរយៈធនាគារទំនាក់ទំនងឆ្លងដែនឬទំនាក់ទំនងដូចនេះផ្សេងទៀត។

២- ក្នុងករណីយោងទៅកថាខណ្ឌទី១នៃមាត្រានេះ បុគ្គលរាយការណ៍ត្រូវស្វែងរកព័ត៌មានបន្ថែមអំពីប្រភពដើមនិងគោលដៅរបស់ប្រាក់ គោលបំណងនៃប្រតិបត្តិការ និងអត្តសញ្ញាណរបស់ភាគីចូលរួមប្រតិបត្តិការ។

**មាត្រា១១ .- ការរក្សាទុកឯកសារកត់ត្រារបស់បុគ្គលរាយការណ៍**

បុគ្គលរាយការណ៍ដូចមានចែងក្នុងមាត្រា៤នៃច្បាប់នេះត្រូវរក្សាទុកឯកសារកត់ត្រាអត្តសញ្ញាណនិងប្រតិបត្តិការរបស់អតិថិជនឱ្យបានគ្រប់គ្រាន់យ៉ាងតិចបំផុត៥(ប្រាំ)ឆ្នាំ ក្រោយគណនីត្រូវបានបិទឬទំនាក់ទំនងអាជីវកម្មជាមួយអតិថិជនត្រូវបានបញ្ចប់ និងត្រូវរក្សាទុកសម្រាប់តម្រូវការរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីអាចមើលឡើងវិញនូវប្រតិបត្តិការនីមួយៗ រួមមានចំនួនប្រាក់ និងប្រភេទរូបិយប័ណ្ណបើមាន ដើម្បីផ្តល់ភស្តុតាងសមស្របសម្រាប់ផ្តន្ទាទោសជនល្មើស។

**មាត្រា១២ .- របាយការណ៍អំពីប្រតិបត្តិការសាច់ប្រាក់ឬប្រតិបត្តិការសង្ស័យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

១- បុគ្គលរាយការណ៍ដូចមានចែងក្នុងមាត្រា៤នៃច្បាប់នេះត្រូវរាយការណ៍ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានូវប្រតិបត្តិការសាច់ប្រាក់ដែលស្មើឬលើសពីចំនួនកំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក៏ដូចជាប្រតិបត្តិការណាដែលពាក់ព័ន្ធប្រតិបត្តិការសាច់ប្រាក់ច្រើនដង ហើយចំនួនប្រាក់សរុបលើសពីចំនួនដែលបានកំណត់នេះ។

២- ដោយពុំគិតដល់កាតព្វកិច្ចរាយការណ៍ដែលបានកំណត់ក្នុងកថាខណ្ឌទី១នៃមាត្រានេះ បើបុគ្គលរាយការណ៍សង្ស័យឬមានមូលដ្ឋានសមស្រប ដើម្បីសង្ស័យថាមូលនិធិជាផលបានមកពីការប្រព្រឹត្តបទល្មើសឬជាប់ទាក់ទងដល់ហិរញ្ញប្បទានភេរវកម្ម បុគ្គលរាយការណ៍ត្រូវរាយការណ៍ជាបន្ទាន់ក្នុងរយៈពេល២៤ម៉ោង ពីការសង្ស័យរបស់ខ្លួនទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

៣- របាយការណ៍ពីការសង្ស័យត្រូវបញ្ជូនទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាតាមមធ្យោបាយទំនាក់ទំនងឆាប់រហ័សណាមួយ ដូចជា ទូរសារ ឬប្រសិនបើគ្មាន តាមរយៈលិខិតជាលាយលក្ខណ៍អក្សរ។ របាយការណ៍តាមទូរស័ព្ទត្រូវបញ្ជាក់បន្ថែមតាមទូរសារឬលិខិតជាលាយលក្ខណ៍អក្សរក្នុងរយៈពេលមួយខ្លីបំផុតដែលអាចធ្វើបាន។ នៅពេលទទួលបានរបាយការណ៍ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវបញ្ជាក់ថាបានទទួល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៤- បុគ្គលរាយការណ៍ដែលបានផ្ញើរបាយការណ៍ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក៏ដូចជាក្រសួង ស្ថាប័នផ្សេងទៀតដែលមានព័ត៌មានទាក់ទងដល់ប្រតិបត្តិការឬដល់អតិថិជនដែលជាប់ពាក់ព័ន្ធនៅក្នុងរបាយការណ៍ ត្រូវផ្ដល់ឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាឬក្រសួង ស្ថាប័នអនុវត្តច្បាប់ដែលកំពុងស៊ើបអង្កេត ដោយផ្ដើមចេញពី ឬទាក់ទងដល់ព័ត៌មាននៅក្នុងរបាយការណ៍និងព័ត៌មានផ្សេងទៀត ដែលមានអំពីប្រតិបត្តិការឬប្រតិបត្តិការដែលត្រូវបានប៉ុនប៉ងធ្វើឬភាគីចូលរួមក្នុងប្រតិបត្តិការ បើមានការស្នើសុំពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ឬក្រសួង ស្ថាប័នអនុវត្តច្បាប់។

៥- បើអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាមានមូលដ្ឋានសមហេតុផលក្នុងការសង្ស័យថា ប្រតិបត្តិការ ឬសំណើប្រតិបត្តិការមួយអាចជាប់ពាក់ព័ន្ធបទល្មើសសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ឬសម្រាប់ករណីប្រាកដប្រជាឬបន្ទាន់ បើយល់ថាចាំបាច់ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាអាចណែនាំបុគ្គលរាយការណ៍ជាលាយលក្ខណ៍អក្សរឬតាមទូរស័ព្ទ បន្ទាប់មកជាលាយលក្ខណ៍អក្សរ មិនឱ្យបន្តដំណើរការប្រតិបត្តិការនោះ ឬប្រតិបត្តិការដែលបានធ្វើ ឬប្រតិបត្តិការផ្សេងណាដែលមានមូលនិធិទាក់ទងដល់ប្រតិបត្តិការនោះ ឬប្រតិបត្តិការដែលបានស្នើក្នុងរយៈពេលមួយដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានកំណត់មិនឱ្យលើសពី៤៨ម៉ោង ដើម្បីឱ្យអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អាច៖

ក- ធ្វើការស៊ើបអង្កេតចាំបាច់អំពីប្រតិបត្តិការ។

ខ- ផ្ដល់ព័ត៌មាននិងផ្ដល់យោបល់ទៅក្រសួង ស្ថាប័នអនុវត្តច្បាប់ បើយល់ថាសមស្រប។

**មាត្រា១៣ .– ខ្លឹមសារនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ**

របាយការណ៍ប្រតិបត្តិការសង្ស័យដែលត្រូវបានផ្ញើទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវមានភ្ជាប់មកជាមួយជាអប្បបរមានូវ៖

១- អត្តសញ្ញាណនិងសញ្ញាណសម្គាល់របស់បុគ្គលរាយការណ៍ រួមទាំង ឈ្មោះនិងព័ត៌មានលម្អិតសម្រាប់ទាក់ទងនៃមន្ត្រីរាយការណ៍។

២- អត្តសញ្ញាណនិងសញ្ញាណសម្គាល់របស់អតិថិជននិងអត្ថគាហកដែលពាក់ព័ន្ធក្នុងប្រតិបត្តិការនោះ។

៣- ប្រភេទនិងព័ត៌មានលម្អិតនៃប្រតិបត្តិការ ដូចជា ចំនួនប្រាក់ រូបិយប័ណ្ណ កាលបរិច្ឆេទ ភាគីពាក់ព័ន្ធដែលត្រូវបានរាយការណ៍ថាសង្ស័យ រួមមាន លេខគណនី សញ្ញាណសម្គាល់របស់ម្ចាស់គណនីនោះ។

៤- ពិពណ៌នាដោយសង្ខេបពីកាលៈទេសៈនិងហេតុផលផ្សេងៗ ដែលបង្ហាញឱ្យឃើញថាជាប្រតិបត្តិការសង្ស័យ។

**មាត្រា១៤ .– ការរួចផុតពីការទទួលខុសត្រូវចំពោះការរាយការណ៍ដោយសុចរិតនូវប្រតិបត្តិការសាច់ប្រាក់ ឬប្រតិបត្តិការសង្ស័យ**

បុគ្គលនាយក និយោជិត ឬបុគ្គលរាយការណ៍៖

១- ដែលបានបញ្ជូនព័ត៌មានឬធ្វើរបាយការណ៍ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាដោយសុចរិតស្របតាមច្បាប់នេះ មិនត្រូវបានប្ដឹងចោទប្រកាន់ណាមួយពីបទរំលោភលើការហាមឃាត់ក្នុងការបើកចំហព័ត៌មាន ឬការសម្ងាត់ធនាគារ ឬការសម្ងាត់វិជ្ជាជីវៈឡើយ។

២- ដែលបានបញ្ជូនព័ត៌មានឬធ្វើរបាយការណ៍ដោយសុចរិតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ មិនត្រូវបានតម្រូវឱ្យទទួលខុសត្រូវពីផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ក៏ដូចជាមិនត្រូវទទួលទណ្ឌកម្មខាងវិជ្ជាជីវៈណាមួយឡើយ ទោះបីជាមានការស៊ើបអង្កេតក៏មិនអាចនាំទៅដល់ការផ្ដន្ទាទោសដែរ។

៣- មិនត្រូវបានតម្រូវឱ្យទទួលខុសត្រូវពីផ្នែករដ្ឋបាល ផ្នែករដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ដោយហេតុផលថាបានបង្កការខាតបង់ណាមួយខាងសម្ភារៈ និង/ឬមិនមែនសម្ភារៈ កើតឡើងដោយសារការព្យួរប្រតិបត្តិការ ដូចមានចែងក្នុងកថាខណ្ឌទី៥នៃមាត្រា១២នៃច្បាប់នេះ។

**មាត្រា១៥._ ការហាមឃាត់ការផ្ដល់ព័ត៌មាន**

ក្នុងកាលៈទេសៈណាក៏ដោយ បុគ្គលដែលមានកាតព្វកិច្ចផ្ដល់ព័ត៌មានឬបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា១៣ ឬបុគ្គលណាដែលបានដឹងរឿងមិនត្រូវផ្ដល់ព័ត៌មានឬរបាយការណ៍ទាំងនោះទៅបុគ្គលផ្សេងក្រៅពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាទេ លើកលែងតែមានការអនុញ្ញាតពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

**មាត្រា១៦ ._ ការត្រួតពិនិត្យផ្ទៃក្នុងនិងការប្រតិបត្តិតាមរបស់បុគ្គលរាយការណ៍**

បុគ្គលរាយការណ៍ដូចមានចែងក្នុងមាត្រា៤នៃច្បាប់នេះ ត្រូវបង្កើតកម្មវិធីសម្រាប់ទប់ស្កាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មតាមការណែនាំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។ កម្មវិធីទាំងនេះរួមមាន៖

១- ការបង្កើតគោលនយោបាយ នីតិវិធី និងការត្រួតពិនិត្យផ្ទៃក្នុង រួមមាន ការរៀបចំការប្រតិបត្តិឱ្យបានសមស្រប និងនីតិវិធីតាមដានគ្រប់គ្រាន់ ដើម្បីធានាឱ្យមានលក្ខណសម្បត្តិខ្ពស់នៅពេលជ្រើសរើសនិយោជិត។

២- ការតែងតាំងមន្ត្រីប្រតិបត្តិជាមន្ត្រីថ្នាក់គ្រប់គ្រង។

៣- ការបណ្ដុះបណ្ដាលមន្ត្រីបុគ្គលិកជាប្រចាំ។

៤- មុខងារត្រួតពិនិត្យផ្ទៃក្នុងដើម្បីផ្ទៀងផ្ទាត់ការប្រតិបត្តិនិងប្រសិទ្ធភាពនៃរាល់វិធានការដែលត្រូវប្រកាន់យកដើម្បីអនុវត្តច្បាប់នេះ។

**មាត្រា១៧ ._ មន្ត្រីប្រតិបត្តិ**

មន្ត្រីប្រតិបត្តិដែលត្រូវបានតែងតាំងស្របតាមកថាខណ្ឌទី២នៃមាត្រា១៦នៃច្បាប់នេះ ជាមន្ត្រីជាន់ខ្ពស់មានគុណវុឌ្ឍិនិងបទពិសោធន៍គ្រប់គ្រាន់ ដែលអាចមានលទ្ធភាពឆ្លើយតបបានល្អត្រឹមត្រូវទៅនឹង[illegible]ទាក់ទងជាមួយបុគ្គលរាយការណ៍និងដំណើរការអាជីវកម្មរបស់បុគ្គលនោះ ព្រមទាំងអាចទទួល[illegible]បរមា៖

១- ដើម្បីបង្កើតនិងថែរក្សាគោលនយោបាយផ្ទៃក្នុង នីតិវិធី និងសៀវភៅណែនាំពីការប្រតិបត្តិ។

២- ដើម្បីធានាឱ្យបុគ្គលិករបស់បុគ្គលរាយការណ៍ប្រតិបត្តិបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ផ្សេងទៀតដែលទាក់ទងដល់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងបទប្បញ្ញត្តិនៃគោលនយោបាយ នីតិវិធី និងសៀវភៅណែនាំពីការប្រតិបត្តិដែលបានបង្កើតឡើងស្របតាមមាត្រានេះ។

៣- ដើរតួជាអ្នកទំនាក់ទំនងរវាងបុគ្គលរាយការណ៍និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក្នុងការងារដែលទាក់ទងដល់ការប្រតិបត្តិបទប្បញ្ញត្តិនៃច្បាប់នេះនិងច្បាប់ផ្សេងទៀត ដែលចែងអំពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

**មាត្រា១៨ ._ កាតព្វកិច្ចសមស្របនិងត្រឹមត្រូវ**

ក្រសួង ស្ថាប័នត្រួតពិនិត្យត្រូវធានាថា គណៈគ្រប់គ្រងនិងភាគទុនិករបស់បុគ្គលរាយការណ៍មានលក្ខណៈសមស្របនិងត្រឹមត្រូវ ដើម្បីអាចទប់ស្កាត់ឧក្រិដ្ឋជននិងសមាគតមិនឱ្យកាន់កាប់ ឬក្លាយជាអត្ថគាហក ឬជាអ្នកកាន់កាប់ផលប្រយោជន៍សំខាន់ៗ ឬមុខងារគ្រប់គ្រងនៅក្នុងអង្គភាពទាំងនោះ។

## ជំពូកទី៤
## ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

**មាត្រា១៩ ._ ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម**

១- ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម រួមមានក្រុមប្រឹក្សាភិបាលនិងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

២- ស្ថាប័នប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មត្រូវមានរូបសញ្ញានិងត្រាសម្រាប់ប្រើប្រាស់ក្នុងដំណើរការការងាររបស់ខ្លួន ដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២០ ._ ក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

១- ត្រូវបានបង្កើតក្រុមប្រឹក្សាភិបាលនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលតទៅនេះហៅថា ក្រុមប្រឹក្សាភិបាល ដែលមានតួនាទីពិគ្រោះយោបល់និងផ្តល់អនុសាសន៍លើការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ក្រុមប្រឹក្សាភិបាលរួមមានមន្ត្រីជាន់ខ្ពស់តំណាងឱ្យក្រសួង ស្ថាប័នដូចខាងក្រោម៖

ក- ទីស្តីការគណៈរដ្ឋមន្ត្រី

ខ- ក្រសួងយុត្តិធម៌

គ- ក្រសួងមហាផ្ទៃ

ឃ- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ង- ធនាគារជាតិនៃកម្ពុជា

ច- ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ជាលេខាធិការ។

២- សមាសភាពជាក់ស្តែងនៃក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ធនាគារជាតិនៃកម្ពុជា។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣- ប្រធានក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់ធនាគារជាតិនៃកម្ពុជា ដោយជ្រើសរើសចេញពីតំណាងក្រសួង ស្ថាប័ន ដូចបានរៀបរាប់ខាងលើសម្រាប់រយៈពេល២(ពីរ)ឆ្នាំ។ ប្រធានក្រុមប្រឹក្សាភិបាលអាណត្តិទីមួយត្រូវតែជាតំណាងធនាគារជាតិនៃកម្ពុជា។

**មាត្រា២១ ._ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

១- ត្រូវបានបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលស្ថិតក្រោមធនាគារជាតិនៃកម្ពុជា។

២- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវធ្វើការដោយស្ថិតនៅក្រោមឱវាទក្រុមប្រឹក្សាភិបាល។

៣- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវដឹកនាំដោយប្រធាន១(មួយ)រូប មានឋានៈស្មើអគ្គនាយក និងមានអនុប្រធានមួយចំនួនមានឋានៈស្មើអគ្គនាយករងជាជំនួយការតាមការចាំបាច់។ ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីទទួលការស្នើសុំពីធនាគារជាតិនៃកម្ពុជា។ អនុប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ធនាគារជាតិនៃកម្ពុជា។

៤- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវមានធនធានគ្រប់គ្រាន់និងសិទ្ធិអំណាចធ្វើការសម្រេចចិត្តដោយឯករាជ្យក្នុងការងារដែលស្ថិតក្នុងដែននៃការទទួលខុសត្រូវរបស់ខ្លួន។

៥- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវមានមន្ត្រីនិងបុគ្គលិកគ្រប់គ្រាន់។ មន្ត្រីនិងបុគ្គលិកត្រូវមានលក្ខណៈសម្បត្តិសុចរិតកម្រិតខ្ពស់ស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

៦- ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២២ ._ មុខងារនិងភារកិច្ចរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាមានមុខងារនិងភារកិច្ចដូចខាងក្រោម៖

១- ទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យនិងប្រតិបត្តិការសាច់ប្រាក់ ដែលធ្វើឡើងស្របតាមមាត្រា១២នៃច្បាប់នេះ និងព័ត៌មានស្តីពីការសង្ស័យនៃការសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម ដែលត្រូវបានផ្ញើមក។

២- ប្រមូលព័ត៌មានដែលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាយល់ថាទាក់ទងដល់សកម្មភាពរបស់ខ្លួនស្តីពីការសម្អាតប្រាក់ឬហិរញ្ញប្បទានភេរវកម្ម ហើយដែលមានផ្សព្វផ្សាយជាសាធារណៈ រួមមាន ទិន្នន័យពាណិជ្ជកម្ម ក៏ដូចជាព័ត៌មានផ្សេងៗទៀតដែលចាំបាច់សម្រាប់អនុវត្តមុខងាររបស់ខ្លួន ដូចជា ព័ត៌មានដែលបានប្រមូល និងថែរក្សាទុកក្នុងទិន្នន័យដោយបុគ្គលរាយការណ៍។

៣- យកតាមកាលានុវត្តស្របតាមច្បាប់នូវព័ត៌មានហិរញ្ញវត្ថុ រដ្ឋបាល និងព័ត៌មានសម្រាប់ការពង្រឹងការអនុវត្តច្បាប់ ដែលចាំបាច់សម្រាប់ការបំពេញមុខងាររបស់ខ្លួន ដូចមានចែងក្នុងមាត្រានេះ រួមទាំងព័ត៌មានដែលត្រូវបានប្រមូលនិងថែរក្សាទុកក្នុងទិន្នន័យរបស់ក្រសួង ស្ថាប័នសាធារណៈផ្សេងៗ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៤- វិភាគនិងវាយតម្លៃ នូវរាល់របាយការណ៍ប្រតិបត្តិការសង្ស័យនិងព័ត៌មានពាក់ព័ន្ធ ដើម្បីកំណត់ពីមូលដ្ឋានសមស្របដែលនាំឱ្យជឿជាក់ថាបទល្មើសសម្អាតប្រាក់ឬបទល្មើសហិរញ្ញប្បទានភេរវកម្មបានកើតឡើង ហើយក្នុងករណីនេះ ត្រូវបញ្ជូនសំណុំរឿងទៅក្រសួង ស្ថាប័នអនុវត្តច្បាប់ដើម្បីស៊ើបអង្កេតពីបទល្មើស។

៥- ចងក្រងស្ថិតិនិងកត់ត្រាអំពីរបាយការណ៍ប្រតិបត្តិការសង្ស័យនិងប្រតិបត្តិការសាច់ប្រាក់ដែលបានទទួលវិភាគ និងបញ្ជូនទៅក្រសួង ស្ថាប័នអនុវត្តច្បាប់ និងផ្តល់ព័ត៌មានទាំងនោះទៅក្រសួង ស្ថាប័នសាធារណៈផ្សេងទៀត យោងតាមរឿងហេតុដែលពាក់ព័ន្ធ។

៦- ផ្តល់មតិទៅបុគ្គលរាយការណ៍ និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងៗ នូវលទ្ធផលនៃរបាយការណ៍ប្រតិបត្តិការសង្ស័យឬព័ត៌មានផ្សេងៗ ដូចមានចែងនៅក្នុងច្បាប់នេះ។

៧- ធានាថារាល់ព័ត៌មានផ្ទាល់ខ្លួនដែលស្ថិតនៅក្នុងដៃរបស់ខ្លួន ត្រូវបានការពារមិនឱ្យបើកចំហដោយគ្មានការអនុញ្ញាត។

៨- ចាត់វិធានការដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការងារទាក់ទងដល់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។

**មាត្រា២៣ .- ការត្រួតពិនិត្យដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**

១- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវចេញសេចក្តីណែនាំទៅបុគ្គលរាយការណ៍ស្តីពីការសម្គាល់អត្តសញ្ញាណរបស់អតិថិជន ការរក្សាទុកឯកសារកត់ត្រា ការរាយការណ៍ប្រតិបត្តិការសង្ស័យ និងកាតព្វកិច្ចផ្សេងទៀតស្របតាមច្បាប់នេះ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នត្រួតពិនិត្យមានសមត្ថកិច្ច ក្នុងករណីដែលការត្រួតពិនិត្យដូចនេះត្រូវបានធ្វើរួចហើយ។

២- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវធានាពីការប្រតិបត្តិរបស់បុគ្គលរាយការណ៍ស្របតាមកាតព្វកិច្ចនានាដែលចែងក្នុងច្បាប់នេះ តាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងស្របតាមច្បាប់ដែលពាក់ព័ន្ធ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវសម្របសម្រួលការងារត្រួតពិនិត្យការប្រតិបត្តិតាមច្បាប់នេះជាមួយក្រសួង ស្ថាប័នត្រួតពិនិត្យដែលមានស្រាប់។

៣- ក្នុងពេលត្រួតពិនិត្យ បើរកឃើញការមិនប្រតិបត្តិតាមបទប្បញ្ញត្តិនៃច្បាប់នេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាអាចៈ

ក- ណែនាំបុគ្គលរាយការណ៍ឱ្យប្រកាន់យកសកម្មភាពកែតម្រូវ ដូចដែលបានកំណត់។

ខ- ជូនព័ត៌មានទៅក្រសួង ស្ថាប័នត្រួតពិនិត្យផ្សេងទៀតអំពីការមិនប្រតិបត្តិតាម និងលើកសំណើឱ្យក្រសួង ស្ថាប័នទាំងនោះអនុវត្តវិធានការត្រួតពិនិត្យ រួមមានការដាក់ទណ្ឌកម្ម ឬការដកហូតអាជ្ញាប័ណ្ណតាមសមត្ថកិច្ចរៀងខ្លួន។

គ- ដាក់ទណ្ឌកម្មខាងរដ្ឋបាលស្របតាមច្បាប់នេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា២៤ ._ កាតព្វកិច្ចរក្សាការសម្ងាត់**

ក្រុមប្រឹក្សាភិបាល មន្ត្រី និងបុគ្គលិកនៃអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវមានកាតព្វកិច្ចរក្សាការសម្ងាត់នៃរាល់ព័ត៌មានដែលទទួលបានក្នុងដែននៃភារកិច្ចរបស់ខ្លួន ទោះបីជាក្រោយពេលចប់ភារកិច្ចនៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក៏ដោយ។ រាល់ព័ត៌មានមិនអាចយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងក្រៅពីគោលបំណងដែលបានចែងក្នុងច្បាប់នេះ។

**មាត្រា២៥ ._ មូលដ្ឋានទិន្នន័យ**

យោងតាមច្បាប់និងបទប្បញ្ញត្តិស្ដីពីការការពារសិទ្ធិឯកជន និងមូលដ្ឋានទិន្នន័យប្រព័ន្ធកុំព្យូទ័រ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវដំណើរការមូលដ្ឋានទិន្នន័យដែលមានព័ត៌មានស្ដីពីរបាយការណ៍ប្រតិបត្តិការសង្ស័យនិងប្រតិបត្តិការសាច់ប្រាក់ដូចដែលបានតម្រូវដោយច្បាប់នេះ។ ព័ត៌មានទាំងនោះត្រូវតែបានធ្វើបច្ចុប្បន្នកម្មនិងរៀបចំក្នុងន័យដើម្បីធានាប្រសិទ្ធភាពជាអតិបរមានៃការវិភាគប្រតិបត្តិការរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងជួយបញ្ជាក់ថាជាការពិតឬធ្វើទុព្វលកម្មការសង្ស័យ។

**មាត្រា២៦ ._ ទំនាក់ទំនងជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេស**

១- យោងតាមការសម្របសម្រួលគ្នាទៅវិញទៅមក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា អាចផ្លាស់ប្ដូរព័ត៌មានជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសបាន លុះណាតែអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេសមានកាតព្វកិច្ចរក្សាការសម្ងាត់ដូចគ្នា ដោយមិនគិតពីប្រភេទនៃអង្គភាពទាំងនោះ។ សម្រាប់គោលបំណងនេះ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាអាចចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយអង្គភាពទាំងនោះបាន។

២- នៅពេលបានទទួលសំណើសុំព័ត៌មានឬការបញ្ជូនព័ត៌មានពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុជាដៃគូនៅបរទេស អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវឆ្លើយតបតាមសំណើក្នុងដែនអំណាចនៃច្បាប់នេះ។

## ជំពូកទី៥
## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា២៧ ._ គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ**

១- ត្រូវបានបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ដើម្បីទទួលបន្ទុករៀបចំដាក់ចេញនូវគោលនយោបាយ ដឹកនាំ និងសម្របសម្រួលការអនុវត្តច្បាប់នេះ។

២- ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៨ ._ ការសម្របសម្រួលផ្ទៃក្នុងកម្រិតបច្ចេកទេស**

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្រសួង ស្ថាប័នអនុវត្តច្បាប់ ក្រសួង ស្ថាប័នត្រួតពិនិត្យ ព្រមទាំងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀតដែលទទួលខុសត្រូវទប់ស្កាត់ ឬត្រួតពិនិត្យការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ត្រូវបង្កើតយន្តការប្រតិបត្តិរៀងៗខ្លួនសម្រាប់៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

១- ជានាអំពីការផ្លាស់ប្តូរព័ត៌មាននិងការសម្របសម្រួលរវាងក្រសួង ស្ថាប័នទាំងនេះជាមួយវិស័យឯកជនដែលពាក់ព័ន្ធ។

២- ផ្តល់ការណែនាំសម្រាប់ការអនុវត្តច្បាប់នេះ។

៣- អនុវត្តគោលនយោបាយសម្រាប់វិស័យផ្សេងៗ ដែលស្ថិតនៅក្នុងដែនកំណត់នៃការអនុវត្តច្បាប់នេះ។

**មាត្រា២៩ ._ ការអនុវត្តរបស់ក្រសួង ស្ថាប័នត្រួតពិនិត្យ**

១- ក្រសួង ស្ថាប័នត្រួតពិនិត្យ ត្រូវដាក់ចេញនូវបទប្បញ្ញត្តិ បទបញ្ជា និងសេចក្តីណែនាំសម្រាប់ការអនុវត្តច្បាប់នេះ ជាពិសេសចំពោះ៖

ក- ការសម្របសម្រួលព័ត៌មានជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដើម្បីស្រុះស្រួលគ្នាអំពីវិធានការទាំងឡាយដែលត្រូវប្រកាន់យកក្នុងការដាក់ទណ្ឌកម្មខាងវិន័យ ឬការបញ្ជូនទៅតុលាការចំពោះបទល្មើសទាំងឡាយដែលបានកើតឡើង។

ខ- ការសម្របសម្រួលរវាងក្រសួង ស្ថាប័នត្រួតពិនិត្យផងគ្នា ដើម្បីដាក់ចេញបទប្បញ្ញត្តិ បទបញ្ជា និងសេចក្តីណែនាំ ដើម្បីអនុវត្តច្បាប់នេះ។

គ- ការចេញបទបញ្ជានិងសេចក្តីណែនាំ ដើម្បីកំណត់តួនាទីនិងភារកិច្ច និងសម្រាប់ការពារមន្ត្រី បុគ្គលិក ដែលបំពេញការងារដោយសុចរិតនៅក្នុងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ការរក្សាការសម្ងាត់នៃព័ត៌មាននិងវិធាននៃការបើកចំហព័ត៌មាន។

២- ក្រសួង ស្ថាប័នត្រួតពិនិត្យ ត្រូវសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាណែនាំបុគ្គលរាយការណ៍ក្នុងការរៀបចំបង្កើតនូវកម្មវិធីទប់ស្កាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មស្របតាមមាត្រា១៦នៃច្បាប់នេះ និងរៀបចំដាក់ចេញនូវគំរូរបាយការណ៍នានាឱ្យស្របតាមរូបភាពនិងចរិតលក្ខណៈនៃបុគ្គលរាយការណ៍ទាំងនេះ។

៣- បទបញ្ជានិងសេចក្តីណែនាំដែលចេញដោយក្រសួង ស្ថាប័នត្រួតពិនិត្យក្រោមច្បាប់នេះ អាចកែប្រែឬធ្វើវិសោធនកម្មក្នុងកាលៈទេសៈសមស្រប ឬនៅពេលដែលមានការចាំបាច់។

**មាត្រា៣០ ._ ការកម្រិតការប្រើប្រាស់សាច់ប្រាក់ក្នុងប្រតិបត្តិការពាណិជ្ជកម្ម**

រាជរដ្ឋាភិបាលត្រូវមានវិធានការសមស្របដើម្បីកាត់បន្ថយចរាចរណ៍និងការប្រើប្រាស់សាច់ប្រាក់ក្នុងប្រតិបត្តិការពាណិជ្ជកម្ម និងលើកទឹកចិត្តឱ្យប្រើប្រាស់មធ្យោបាយទូទាត់មិនមែនសាច់ប្រាក់ ដែលជួយសម្រួលដល់ការសម្គាល់អត្តសញ្ញាណរបស់ភាគីដែលចូលរួម។

## ជំពូកទី៦
## ការបង្កក ការឃាត់ទុក និងការរឹបអូស

**មាត្រា៣១ ._ ការបង្កកនិងការឃាត់ទុកទ្រព្យសម្បត្តិរបស់បុគ្គល**

១- សមាជិកដែលត្រូវបានចាត់តាំងដោយគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិអាចបង្កកទ្រព្យសម្បត្តិ និងចាត់វិធានការបណ្តោះអាសន្នសមស្របផ្សេងទៀត កាន់តែឆាប់តាមដែលអាចធ្វើទៅបាន នៅពេលមានការសង្ស័យឬមានមូលដ្ឋានសមស្របសង្ស័យថា ទ្រព្យសម្បត្តិ

នោះពាក់ព័ន្ធនឹងបទល្មើសឬផលនៃបទល្មើស មុននឹងស្នើសុំសេចក្តីសម្រេចពីតុលាការក្នុងគោលបំណងរក្សាទុកទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការរឹបអូសដូចមានចែងក្នុងមាត្រា៣២ (ការរឹបអូសទ្រព្យសម្បត្តិ) នៃច្បាប់នេះ។

២- ក្រសួង ស្ថាប័នអនុវត្តច្បាប់ ក្រោយពេលដឹងថា មានវត្តមាននៃទ្រព្យសម្បត្តិដែលពាក់ព័ន្ធ ឬសង្ស័យថាពាក់ព័ន្ធនឹងបទល្មើស ឬផលនៃបទល្មើស ត្រូវតែឃាត់ទុកទ្រព្យសម្បត្តិនោះដោយគ្មានបង្អង់ និងយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន ហើយប្តឹងសុំទៅតុលាការ ដើម្បីបង្កកទ្រព្យសម្បត្តិនោះ។

**មាត្រា៣២._ ការរឹបអូសទ្រព្យសម្បត្តិ**

១- ក្នុងស្ថានភាពមានទោសសម្អាតប្រាក់ ឬសំអាងនៃបទល្មើស ឬហិរញ្ញប្បទានភេរវកម្ម តុលាការអាចចេញបទបញ្ជាឱ្យរឹបអូស៖

ក- ទ្រព្យសម្បត្តិដែលជាផលបទល្មើស រួមទាំងទ្រព្យសម្បត្តិរួមបញ្ចូលគ្នា ឬត្រូវបានផ្លាស់ប្តូរជាមួយផលទាំងនោះ ឬ

ខ- ទ្រព្យសម្បត្តិដែលជាចំណូល ឬអត្ថប្រយោជន៍ផ្សេងទៀតដែលទទួលបានពីផលនៃបទល្មើស ឬ

គ- ឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ

ឃ- ទ្រព្យសម្បត្តិដែលមានចែងនៅចំណុច «ក» ដល់ ចំណុច «គ» នៃមាត្រានេះដែលត្រូវបានផ្ទេរទៅភាគីណាមួយ លើកលែងតែមានភស្តុតាងបញ្ជាក់ថាម្ចាស់កម្មសិទ្ធិនៃទ្រព្យសម្បត្តិនោះទទួលបានដោយបានបង់ថ្លៃត្រឹមត្រូវ ឬសម្រាប់ការផ្តល់សេវាត្រឡប់វិញស្របតាមតម្លៃនៃទ្រព្យសម្បត្តិ ឬលើមូលដ្ឋានស្របច្បាប់ណាមួយផ្សេងទៀត និងថាបុគ្គលនោះ មិនបានដឹងពីប្រភពមិនស្របច្បាប់នៃទ្រព្យសម្បត្តិនោះ ឬ

ង- ទ្រព្យសម្បត្តិរបស់ចារីដែលពាក់ព័ន្ធបទល្មើសដែលមានតម្លៃស្មើនឹងតម្លៃនៃផលនៃបទល្មើស។

២- ក្នុងករណីតុលាការរកឃើញបទល្មើសមានពាក់ព័ន្ធនឹងការសម្អាតប្រាក់ ឬសំអាងនៃបទល្មើស ឬហិរញ្ញប្បទានភេរវកម្ម ទោះបីជាចារីមិនទាន់ត្រូវបានផ្តន្ទាទោសដោយសារមិនស្គាល់អត្តសញ្ញាណ ឬស្លាប់ តុលាការនៅតែអាចចេញបញ្ជារឹបអូសទ្រព្យសម្បត្តិដែលត្រូវបានឃាត់ទុក ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ទ្រព្យសម្បត្តិនោះជាផលនៃបទល្មើស។

៣- បន្ថែមពីការរឹបអូសទ្រព្យសម្បត្តិដែលមានចែងក្នុងចំណុច «ក» ដល់ ចំណុច «ង» នៃមាត្រានេះ ការរឹបអូសទ្រព្យសម្បត្តិដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏ត្រូវបានអនុវត្តផងដែរ។

**មាត្រា៣៣ ._ ទ្រព្យសម្បត្តិបញ្ចូលគ្នា**

នៅពេលណាដែលទ្រព្យសម្បត្តិដែលជា ឬត្រូវបានសង្ស័យដោយសមហេតុផលថាជាទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសឬជាផលនៃបទល្មើស ត្រូវបានដាក់បញ្ចូលជាមួយទ្រព្យសម្បត្តិដទៃទៀតដែលមិនពាក់ព័ន្ធនឹងបទល្មើសឬផលនៃបទល្មើស ត្រូវបានរឹបអូសតាមបញ្ញត្តិនៃមាត្រា៣១(ការបង្កកនិងការរឹបអូសទ្រព្យសម្បត្តិរបស់បុគ្គល) ឬមាត្រា៣២(ការរឹបអូសទ្រព្យសម្បត្តិ)នៃច្បាប់នេះ ត្រូវតែមិន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

លើសតម្លៃនៃទ្រព្យសម្បត្តិដែលជា ឬត្រូវបានសង្ស័យ ដោយសមហេតុផលថាជាទ្រព្យសម្បត្តិទាក់ទងនឹងបទល្មើស ឬផលនៃបទល្មើស។

**មាត្រា៣៤ ._ បន្ទុករបស់ជនជំទាស់នឹងសេចក្ដីសម្រេច**

ជនដែលជំទាស់នឹងសេចក្ដីសម្រេចតាមបញ្ញត្តិនៃមាត្រា៣១(ការបង្កកនិងការឃាត់ទុកទ្រព្យសម្បត្តិរបស់បុគ្គល) ឬមាត្រា៣២(ការរឹបអូសទ្រព្យសម្បត្តិ)ខាងលើនេះ ដែលសុំដកទ្រព្យសម្បត្តិដែលត្រូវបានសម្រេចឱ្យដក ឬរឹបអូស ឬដែលសុំបដិសេធសេចក្ដីសម្រេចនេះត្រូវតែបង្ហាញតុលាការថា ជននោះមានសិទ្ធិដោយត្រឹមត្រូវលើទ្រព្យសម្បត្តិនោះ ហើយទ្រព្យសម្បត្តិនោះមិនជាប់ពាក់ព័ន្ធនឹងបទល្មើសឬផលនៃបទល្មើស។

**មាត្រា៣៥ ._ ការបង្កកមូលនិធិទាក់ទងនឹងហិរញ្ញប្បទានភេរវកម្ម**

ទោះបីមានបទប្បញ្ញត្តិច្បាប់ផ្សេងទៀតក៏ដោយ មូលនិធិរបស់ភេរវករ របស់អ្នកផ្ដល់ហិរញ្ញប្បទានភេរវកម្ម និងរបស់អង្គការភេរវកម្មដែលកំណត់ដោយសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ១២៦៧ លេខ១៣៧៣ និងសេចក្ដីសម្រេចបន្តបន្ទាប់ ត្រូវបានបង្កកដោយគ្មានពន្យារពេលតាមយន្តការនិងនីតិវិធីដែលមានកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**មាត្រា៣៦ ._ ទណ្ឌកម្ម**

១- ទណ្ឌកម្មក្នុងច្បាប់នេះ រួមមាន ទណ្ឌកម្មខាងវិន័យ និងទណ្ឌកម្មខាងព្រហ្មទណ្ឌ។

២- ទណ្ឌកម្មខាងវិន័យ រួមមាន៖

ក- ការព្រមាន។

ខ- ការស្ដីបន្ទោស។

គ- ការហាមឃាត់ ឬដាក់កំហិតមិនឱ្យធ្វើប្រតិបត្តិការណាមួយ ឬក្នុងរយៈពេលមួយតាមការកំណត់របស់ក្រសួង ស្ថាប័នត្រួតពិនិត្យ។

ឃ- ការដកហូតអាជ្ញាប័ណ្ណប្រកបអាជីវកម្ម។

ង- ការស្នើឱ្យដកហូតតំណែងមន្ត្រីឬនាយកចាត់ការដែលពាក់ព័ន្ធរបស់បុគ្គលរាយការណ៍ទាំងនោះ។

ច- ការផាកពិន័យ។

៣- ទណ្ឌកម្មខាងព្រហ្មទណ្ឌ រួមមាន ការពិន័យជាប្រាក់ និងការដាក់ពន្ធនាគារ។

**មាត្រា៣៧ ._ សិទ្ធិអំណាចរបស់ក្រសួង ស្ថាប័នត្រួតពិនិត្យទាក់ទងនឹងទណ្ឌកម្មខាងវិន័យ**

១- បុគ្គលរាយការណ៍ណាដែលមិនប្រតិបត្តិតាមបញ្ញត្តិនៃមាត្រា៧ដល់មាត្រា១២ និងមាត្រា១៦នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា៣៦នៃច្បាប់នេះ។ ការដាក់ទណ្ឌកម្មខាងវិន័យនេះ គឺជាសិទ្ធិអំណាចរបស់ក្រសួង ស្ថាប័នត្រួតពិនិត្យដែលត្រូវអនុវត្តស្របតាមច្បាប់និងបទដ្ឋានគតិយុត្តជាធរមានដែលមានការពាក់ព័ន្ធ។ ក្នុងករណីចាំបាច់ ក្រសួង ស្ថាប័ន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ត្រួតពិនិត្យអាចចេញលិខិតបទដ្ឋានគតិយុត្តក្រោមសមត្ថកិច្ចរបស់ខ្លួនដើម្បីធានាដល់ការអនុវត្តទណ្ឌកម្មខាងវិន័យនេះ។ ក្នុងករណីក្រសួង ស្ថាប័នត្រួតពិនិត្យ សម្រេចដាក់ទណ្ឌកម្មខាងវិន័យជាការផាកពិន័យ ស្របតាមច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន បុគ្គលដែលទទួលរងការសម្រេចនេះមានសិទ្ធិប្ដឹងតវ៉ាទៅតុលាការដែលមានសមត្ថកិច្ចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីសេចក្ដីសម្រេច។

២- បទប្បញ្ញត្តិនៃជំពូកទោល(បទប្បញ្ញត្តិទូទៅ)នៃមាតិកាទី១(បទប្បញ្ញត្តិទូទៅ) ជំពូកទោល(ការបង្ខំដល់រូបកាយ)នៃមាតិកាទី៣(ការបង្ខំដល់រូបកាយ)នៃគន្ថីទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តក្នុងករណីដែលសេចក្ដីសម្រេចអំពីប្រាក់ពិន័យបានចូលជាស្ថាពរ។

៣- ក្រសួង ស្ថាប័នត្រួតពិនិត្យអាចចាត់វិធានការ ដើម្បីឃាត់ទុកជាបណ្ដោះអាសន្ននូវមធ្យោបាយនិងលទ្ធផលនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងអាចចាត់នីតិវិធីស្របតាមច្បាប់ជាធរមានដើម្បីប្ដឹងទៅតុលាការ នៅពេលដែលការរំលោភលើបទប្បញ្ញត្តិនៃច្បាប់នេះនិងបទបញ្ញាទាំងឡាយមានភាពធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណជននិងដល់សន្តិសុខជាតិ។

**មាត្រា៣៨ ._ បទសម្អាតប្រាក់**

១- ការសម្អាតប្រាក់ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល ឬរហូតដល់ស្មើនឹងតម្លៃមូលនិធិឬទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសម្អាតប្រាក់។

២- បទប្បញ្ញត្តិពីមាត្រា៤០៦(ស្ថានទម្ងន់ទោស)ដល់មាត្រា៤០៨(ទោសបន្ថែមៈ ប្រភេទនិងរយៈពេល)នៃក្រមព្រហ្មទណ្ឌត្រូវយកមកអនុវត្ត។

៣- នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌសម្រាប់បទល្មើសសម្អាតប្រាក់។

៤- នីតិបុគ្គលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ២០០ ០០០ ០០០(ពីររយលាន)រៀល ទៅ ១ ០០០ ០០០ ០០០(មួយប៊ីលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា៤៣(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃច្បាប់នេះ។

**មាត្រា៣៩ ._ ការបដិសេធផ្ដល់ព័ត៌មាន**

១- បុគ្គលណាដែលមានចេតនាមិនផ្ដល់ព័ត៌មានដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជានិងក្រសួង ស្ថាប័នត្រួតពិនិត្យដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ)ថ្ងៃ ទៅ ១(មួយ)ខែ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ទៅ ១០០ ០០០ ០០០(មួយរយលាន)រៀល ឬទោសណាមួយនៃទោសទាំងពីរ។

២- នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តក្នុងកថាខណ្ឌទី១នៃមាត្រានេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៣- នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ ២០០ ០០០ ០០០(ពីររយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា៤៣(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃច្បាប់នេះ។

**មាត្រា៤០ ._ ការខកខានមិនបានធ្វើរបាយការណ៍ប្រតិបត្តិការ**

១- បុគ្គលណាដែលមានចេតនាមិនរាយការណ៍អំពីប្រតិបត្តិការសាច់ប្រាក់ឬប្រតិបត្តិការសង្ស័យទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដូចមានចែងក្នុងមាត្រា១២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ខែ ទៅ ១(មួយ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន)រៀល ទៅ ២០០ ០០០ ០០០(ពីររយលាន)រៀល ឬទោសណាមួយនៃទោសទាំងពីរ។

២- នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

៣- នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០ ០០០ ០០០(ពីររយលាន)រៀល ទៅ ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា៤៣(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃច្បាប់នេះ។

**មាត្រា៤១ ._ ការរំលោភកាតព្វកិច្ចផ្តល់ព័ត៌មាននិងការហាមឃាត់ការផ្តល់ព័ត៌មាន**

១- បុគ្គលណាដែលមានកាតព្វកិច្ចផ្តល់ព័ត៌មានឬបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា១៣នៃច្បាប់នេះ ឬបុគ្គលណាដែលបានដឹងរឿងហើយមានចេតនាផ្តល់ព័ត៌មាន ឬរាយការណ៍ល្មើសនឹងបទប្បញ្ញត្តិនៃការហាមឃាត់ការផ្តល់ព័ត៌មាន ដូចមានចែងក្នុងមាត្រា១៥នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ ១(មួយ)ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ ២០០ ០០០ ០០០(ពីររយលាន)រៀល ឬទោសណាមួយនៃទោសទាំងពីរ។

២- នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តក្នុងកថាខណ្ឌទី១នៃមាត្រានេះ។

៣- នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០ ០០០ ០០០(ពីររយលាន)រៀល ទៅ ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា៤៣(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃច្បាប់នេះ។

**មាត្រា៤២ ._ ការរំលោភកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ**

១- បុគ្គលណាដែលមានចេតនារំលោភកាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ ដូចមានចែងក្នុងមាត្រា២៤នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ ១(មួយ)ឆ្នាំ និងផ្តន្ទាទោសពិន័យ

ជាប្រាក់ពី ៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ ២០០ ០០០ ០០០(ពីររយលាន)រៀល ឬទោសណាមួយនៃទោសទាំងពីរ។

២- នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តក្នុងកថាខណ្ឌទី១នៃមាត្រានេះ។

៣- នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០ ០០០ ០០០(ពីររយលាន)រៀល ទៅ ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា៤៣(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃច្បាប់នេះ។

**មាត្រា៤៣ ._ ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល**

នីតិបុគ្គលត្រូវផ្តន្ទាទោសបន្ថែមណាមួយឬច្រើន ដូចតទៅនេះ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

២- ការដាក់ឱ្យស្ថិតក្រោមការតាមដានត្រួតពិនិត្យរបស់តុលាការតាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើនតាមបែបបទកំណត់ដោយមាត្រា១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈតាមបែបបទកំណត់ដោយមាត្រា១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ)នៃក្រមព្រហ្មទណ្ឌ។

៥- ការហាមឃាត់ចំពោះការអំពាវនាវជាសាធារណៈដល់ការសន្សំសំចៃតាមបែបបទកំណត់ដោយមាត្រា១៧៤(ការហាមឃាត់ចំពោះការធ្វើការអំពាវនាវជាសាធារណៈឱ្យធ្វើការសន្សំសំចៃ)នៃក្រមព្រហ្មទណ្ឌ។

៦- ការរឹបអូសវត្ថុឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើសតាមបែបបទ ដែលកំណត់ដោយមាត្រា១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩(ការរឹបអូសនិងសិទ្ធិតតិយជន)នៃក្រមព្រហ្មទណ្ឌ។

៧- ការរឹបអូសផលទុននិងទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើសតាមបែបបទ ដែលកំណត់ដោយមាត្រា១៧៨(ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩(ការរឹបអូសនិងសិទ្ធិតតិយជន)នៃក្រមព្រហ្មទណ្ឌ។

៨- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសតាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។

៩- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៤៤ .- បទហិរញ្ញប្បទានភេរវកម្ម**

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ ចំពោះបុគ្គលណាដែលមានចេតនាផ្តល់ ឬប្រមូលនូវទ្រព្យសម្បត្តិ មូលនិធិ ឬសេវាផ្សេងៗក្នុងបំណងប្រើប្រាស់ ឬដោយដឹងថា ទ្រព្យសម្បត្តិ មូលនិធិ ឬសេវានេះ នឹងត្រូវបាន ឬអាចប្រើប្រាស់ទាំងមូល ឬមួយផ្នែកសម្រាប់គាំទ្ររាល់សកម្មភាព ជាអាទិ៍ ការធ្វើដំណើរ ការបណ្តុះបណ្តាល ការរៀបចំ ការចូលរួម ឬការប្រព្រឹត្តអំពើភេរវកម្មរបស់ភេរវករ ឬអង្គការចាត់តាំងរបស់ភេរវកម្មដោយផ្ទាល់ឬដោយប្រយោលសម្រាប់អត្ថប្រយោជន៍របស់៖

ក- បុគ្គលណាមួយដែលបានប្រព្រឹត្តបទល្មើសដូចមានបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម ឬបទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស ឬ

ខ- អង្គភាពដែលជាកម្មសិទ្ធិរបស់ ឬដែលត្រូវបានគ្រប់គ្រងដោយផ្ទាល់ឬដោយប្រយោលដោយបុគ្គលដែលបានបញ្ញត្តិក្នុងចំណុច «ក» ខាងលើនេះ ឬ

គ- បុគ្គល ឬអង្គភាពដែលធ្វើសកម្មភាពក្នុងនាមឬតាមការបញ្ជារបស់បុគ្គល ដែលបានបញ្ញត្តិក្នុងចំណុច «ក» ខាងលើនេះ។

២- អំពើដែលបានបញ្ញត្តិក្នុងកថាខណ្ឌទី១ខាងលើនេះ គឺជាបទល្មើស ទោះបីជាទ្រព្យសម្បត្តិ ឬធនធាន ឬសេវាកម្មមិនត្រូវបានយកទៅប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ដែលមានបញ្ញត្តិក្នុងច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្មឬបទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេសក៏ដោយ។

៣- នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលបានប្រព្រឹត្តក្នុងកថាខណ្ឌទី១នៃមាត្រានេះ។

៤- នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ ០០០(មួយប៊ីលាន)រៀល ទៅ ២ ០០០ ០០០ ០០០(ពីរប៊ីលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា៤៣(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃច្បាប់នេះ។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៤៥ .- ការបន្តសុពលភាព**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៦ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៣ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៤៦ .–** ការបាត់បង់អានុភាពនៃច្បាប់ចាស់

ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៦ ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៣ ត្រូវបាត់បង់អានុភាព និងជំនួសដោយច្បាប់នេះ បន្ទាប់ពីការចូលជាធរមាន។

**មាត្រា៤៧ .–** ការប្រកាសឱ្យប្រើ

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ *សៅរ៍ ៧ កើត* ខែ *អាសាឍ* ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី *២៧* ខែ *មិថុនា* ឆ្នាំ២០២០

*នរោត្តម សីហមុនី*

*៣.៧.២០០៦.៦៧៤*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**